# ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល លើផ្នែកវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា

*អត្ថបទនេះ សង្ខេបចំនុចសំខាន់ៗនៃបទបង្ហាញរបស់ ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ[១] ក្នុងវគ្គទី ១ នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

តើហានិភ័យពីខាងក្រៅ មិនអាចប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាឬ? ចម្លើយ គឺមិនមែនទេ ។ សរសរគ្រឹះនៃកំណើននៅកម្ពុជា ពោលគឺ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម អាចងាយរងគ្រោះខ្លាំង ឬតិច ដោយហានិភ័យមកពីខាងក្រៅ ។ បញ្ហានេះស្តែងឡើងយ៉ាងច្បាស់នាបច្ចុប្បន្ននេះ នៅពេលដែលវិបត្តិបានបញ្ឈប់កំណើនសេដ្ឋកិច្ចពិភពលោក ធ្វើឱ្យបណ្តាប្រទេសជឿនលឿនធ្លាក់ចុះសេដ្ឋកិច្ចធ្ងន់ធ្ងរ បន្ថយបង្អាក់ ផលិតកម្មឧស្សាហកម្ម និងការនាំចេញព្រមទាំង ធ្វើឱ្យប្រជាជនបាត់បង់ទំនុកចិត្តខ្លាំងបំផុត មិនធ្លាប់ជួប ។ ការកែតំរូវបញ្ចុះតួលេខគន់គូរកំណើន របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ជាសញ្ញាប្រាប់ថា វិបត្តិកាន់តែធ្ងន់ធ្ងរឡើង ។ សំរាប់កំណើនសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ២០០៩ IMF បានកែតំរូវបញ្ចុះតួលេខប៉ាន់ស្មានពី ៤,៨% មកត្រឹម -0,៥% ប៉ុន្តែគេរំពឹងថា កំណើននេះនឹងកើនដល់ ៣% វិញ នៅឆ្នាំ២០១០ ។

## ផលប៉ះពាល់លើវិស័យកាត់ដេរ

វិបត្តិសាកល បានបង្ហាញថា វិស័យជំរុញកំណើនទានារបស់កម្ពុជា ងាយរងគ្រោះ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចនៅខាងក្រៅប្រទេស ។ ក្នុងនេះគួរពិនិត្យមើលពីផលប៉ះពាល់នៃវិបត្តិ មកលើឧស្សាហកម្មកាត់ដេរ ដែលជាវិស័យនាំចេញឈានមុខរបស់កម្ពុជា ។ យោងតាមនិន្នាការថ្មីៗ ផលិតផលកាត់ដេររួមចំណែកប្រហែល ៦៥% នៃការនាំចេញសរុបរបស់កម្ពុជា ។ វិស័យកាត់ដេរបានធ្លាក់ចុះលឿនណាស់ ដោយសារជាសំខាន់ កង្វះភាពសំបូរបែបនៃទីផ្សារនាំចេញ និងមុខផលិតផល ។ បន្ទាប់ពីមានកំណើនដល់ ២១% នៅឆ្នាំ២០០៦ តំលៃការនាំចេញសំលៀកបំពាក់ បានកើនត្រឹម ៨% និង ៣,៣% ប៉ុណ្ណោះ នៅឆ្នាំ ២០០៧ និង ២០០៨ (ក្រាហ្វិក ១) ។ ទិន្នន័យថ្មីៗនេះទៀតបង្ហាញថា ស្ថានការណ៍បានប្រែប្រួលកាន់តែអាក្រក់ឡើង ដោយតម្លៃការនាំចេញសំលៀកបំពាក់ប្រចាំខែ បានធ្លាក់ចុះគួរឱ្យបារម្ភមកត្រឹម ១៦៥លានដុល្លារអាមេរិក នៅខែមករា ២០០៩ និង ១០២លានដុល្លារអាមេរិក នៅខែកុម្ភៈ ធៀបនឹងតម្លៃជាមធ្យម ២០០លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ហើយការរួមចុះនេះ ដើរស្របតាមការធ្លាក់ចុះខ្លាំងនៃការលក់រាយនៅសហរដ្ឋអាមេរិក ។ យោងតាមតួលេខថ្មីៗ ជាមធ្យមប្រហែល ៦៥% ទៅ ៧០% នៃការនាំចេញសំលៀកបំពាក់របស់កម្ពុជា គឺឆ្ពោះទៅកាន់សហរដ្ឋអាមេរិក ដូច្នេះការធ្លាក់ចុះសេដ្ឋកិច្ច និងការធ្លាក់ចុះតំរូវការនាំចូលរបស់សហរដ្ឋអាមេរិក បានប៉ះពាល់ជាខ្លាំងដល់វិស័យកាត់ដេរនៅកម្ពុជា ។

សកម្មភាពកាត់ដេរភាគច្រើន ប្រមូលផ្តុំក្នុងផ្នែកមានតំលៃបន្ថែមទាប ដែលរារាំងដល់ការពង្រាយហានិភ័យ ផុសចេញពីវិបត្តិនាពេលថ្មីៗ ។ ការលំបាកដែលវិនិយោគិនបរទេសត្រូវប្រឈម បានចោទបញ្ហាបន្ថែមលើឧស្សាហកម្មកាត់ដេរដែលត្រូវពឹងផ្អែកលើវិនិយោគផ្ទាល់ពីបរទេស ។ ការវិវត្តមិនអំណោយផលទាំងនេះ បានប៉ះពាល់ដោយផ្ទាល់ដល់ដំណើរការរោងចក្រកាត់ដេរ និងការងារផ្នែកនេះ ។ ចំនួនសរុបនៃរោងចក្រកំពុង ដំណើរការបានធ្លាក់ចុះពី ២៩២ នៅចុងឆ្នាំ២០០៨ មកត្រឹម ២៧៧ ក្នុងរយៈពេល ២ខែ

ក្រាហ្វិក ១: ការនាំចេញវាយនភ័ណ្ឌ និងសំលៀកបំពាក់របស់កម្ពុជា ទៅទីផ្សារនានា ឆ្នាំ២០០៤-០៨ (គិតជាលានដុល្លារUS)




*ប្រភព: ក្រសួងពាណិជ្ជកម្ម ថ្ងៃទី៦ មីនា ២០០៩*

ក្រោយមក ។ ក្រាហ្វិក ២ បង្ហាញថា ចំនួនកម្មករកាត់ដេរ កើនខ្ពស់បំផុតដល់ ៣៥២.០០០នាក់ នៅខែកញ្ញា ២០០៨ ហើយក៏ធ្លាក់ចុះមកត្រឹម ៣០១.០០០នាក់ វិញ នៅខែកុម្ភៈ ២០០៩ ដោយមានការបាត់បង់ការងារចំនួន ៥១.០០០កន្លែង ។ ក្រៅពីការបញ្ឈប់ពីការងារ ការព្យាយាមកាត់បន្ថយចំណាយប្រតិបត្តិការរបស់រោងចក្រកាត់ដេរ ក៏បង្កកំណើន ភាពគ្មានការងារធ្វើពេញលេញផងដែរ ។ មានរបាយការណ៍ថា ការនាំចេញស្បែកជើងក៏ធ្លាក់ចុះដែរ ដោយកំណើនប្រចាំឆ្នាំធ្លាក់ចុះពី ៤២,៦% នៅឆ្នាំ២០០៧ មកត្រឹម ៤,៨% នៅឆ្នាំ២០០៨ ។ ជាទូទៅ សហភាពអឺរ៉ុប ជាគោលដៅនៃការនាំចេញស្បែកជើងភាគច្រើន ។

## ផលប៉ះពាល់លើវិស័យទេសចរណ៍ និងសំណង់

វិស័យទេសចរណ៍ នៅតែមានកំណើន ប៉ុន្តែយឺតជាងមុនខ្លាំងណាស់ ។ ភ្ញៀវទេសចរមកដល់កម្ពុជាកើនលើសកំរិត ២លាននាក់ នៅឆ្នាំ២០០៧ ហើយកើនដល់ ២.១លាននាក់ នៅឆ្នាំ២០០៨ ប៉ុន្តែអត្រាកំណើនបានធ្លាក់ចុះខ្លាំង ពីកំរិតមធ្យម ២៥% មកត្រឹម ៥% នៅឆ្នាំ២០០៨ (ក្រាហ្វិក ៣) ។

សកម្មភាពសំណង់ ក៏ឃើញធ្លាក់ចុះយ៉ាងច្បាស់ ។ នៅឆ្នាំ២០០៨ វិនិយោគលើវិស័យសំណង់ ធ្លាក់ចុះ ៤០% ដោយសារការថយចុះវិនិយោគផ្ទាល់ពីបរទេស (FDI) ។ កំណើនសេដ្ឋកិច្ចដ៏ប្រសើររបស់កម្ពុជាកាលពីពេលថ្មីៗ វាជាប់ទាក់ទងយ៉ាងខ្លាំងនឹង FDI ដែលតំណាងឱ្យស្ទើរតែ ៦០% នៃវិនិយោគសរុបក្នុងអំឡុងឆ្នាំ២០០៤ ដល់ ២០០៨ ។ ប៉ុន្តែគួរឱ្យស្តាយ ទិន្នន័យរបស់ IMF ស្តីពីជញ្ជីងទូទាត់ បង្ហាញថា តួលេខប៉ាន់ស្មាន FDI បានធ្លាក់ចុះពី ៨៦៦លានដុល្លារអាមេរិក នៅឆ្នាំ២០០៦ មកត្រឹម ៧៨៥លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ។

ម្យ៉ាងទៀត ទិន្នន័យបានពីធនាគារជាតិនៃកម្ពុជា បានបង្ហាញពីការធ្លាក់ចុះ FDI នៅឆមាសទី២ ឆ្នាំ២០០៨ (ក្រាហ្វិក ៤) ។ IMF បានគន់គូរថា FDI នឹងធ្លាក់ចុះខ្លាំងមកត្រឹម ៤៨៨លានដុល្លារអាមេរិកក្នុងឆ្នាំនេះ ។ វិនិយោគពីកូរ៉េខាងត្បូង មានភាពឈប់ទ្រឹង ដោយសារតែវិបត្តិតូលាទានយ៉ាងធ្ងន់ធ្ងរកើតមានក្នុងប្រទេសនោះ ។ ទោះយ៉ាងនេះក្តី វិនិយោគិនកូរ៉េខាងត្បូងនៅតែមានទំនុកចិត្តខ្ពស់មកលើសេដ្ឋកិច្ចកម្ពុជា ហើយគំរោងខ្នាតតូច នឹងមធ្យមមួយចំនួន នៅតែហូរចូលមកកម្ពុជា ។

---

១ ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ ជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ក្រាហ្វិក ២: ការងារក្នុងវិស័យកាត់ដេរ មករា ២០០៨-កុម្ភៈ ២០០៩ (ពាន់នាក់)




ប្រភព: ក្រសួងពាណិជ្ជកម្ម ថ្ងៃទី៦ មីនា ២០០៩

ក្រាហ្វិក ៣: ភ្ញៀវទេសចរមកដល់ប្រទេសកម្ពុជា




ប្រភព: ក្រសួងទេសចរណ៍

ក្រាហ្វិក ៤: វិនិយោគផ្ទាល់ពីបរទេសសុទ្ធ (គិតជាលានដុល្លារUS)




ប្រភព: របាយការណ៍ប្រចាំត្រីមាសរបស់ធនាគារជាតិនៃកម្ពុជា

## ចក្ខុវិស័យ និងការឆ្លើយតបជាយថាហេតុ

ដូចបានរៀបរាប់ខាងលើ ចក្ខុវិស័យសំរាប់កម្ពុជានៅឆ្នាំ២០០៩ កាន់តែអាប់អួរឡើង ហើយ IMF បានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចនៅឆ្នាំនេះ នឹងធ្លាក់ចុះដល់ -0,៥% ។ កម្ពុជាអាចនឹងចូលដល់ការរួមចុះសេដ្ឋកិច្ច ។ គេទស្សទាយថា សេដ្ឋកិច្ចនឹងរើបឡើងវិញបន្តិចនៅឆ្នាំ២០១០ ប៉ុន្តែហានិភ័យនៃការធ្លាក់ចុះថែមទៀតក៏នៅតែមាន ។ដើម្បីទប់ស្កាត់ការរួមចុះសេដ្ឋកិច្ចដែលកាន់តែគំរាមកំហែងខ្លាំងឡើង ភាគីពាក់ព័ន្ធទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន ហើយរដ្ឋាភិបាលត្រូវតែពង្រឹងកំណែទំរង់នានារបស់ខ្លួន ។ វិធានការផ្សេងៗដែលរដ្ឋាភិបាល បានដាក់ចេញមកទល់ពេលនេះ ដូចជា ការលើកលែងពន្ធបង់មុនលើប្រាក់ចំណេញ ១% ជាដើម ពិតជាមានប្រយោជន៍ និងគួរឱ្យកោតសរសើរ ប៉ុន្តែនៅមានការងារច្រើនទៀតដែលត្រូវធ្វើ ។ យើងត្រូវតែជំទាស់គោលនយោបាយការពារផលិតផលក្នុងស្រុក ព្រោះក្នុងពេលជួបការលំបាកបែបនេះ ប្រទេសនានាតែងចង់បង្កើតរបាំងពាណិជ្ជកម្មដើម្បីការពារសេដ្ឋកិច្ចរបស់ខ្លួន ទោះបីវាប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសឯទៀតក្តី ។ ដំណោះស្រាយដែលសមស្រប គឺ ការបើកចំហពាណិជ្ជកម្ម និងធ្វើសមាហរណកម្មកាន់តែច្រើន ។ ចំពោះកម្ពុជា ការបង្កើនពាណិជ្ជកម្មជាមួយប្រទេសក្នុងតំបន់របស់ខ្លួន អាចផ្តល់ផលចំណេញ ពីព្រោះវាជួយបំបែកពង្រាយហានិភ័យទៅតាមទិសដៅផ្សេងៗកាន់តែច្រើន និងជួយកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្ម ។ ប៉ុន្តែចំណុចសំខាន់ គឺ ការធ្វើសមាហរណកម្មទីផ្សារកាន់តែខ្លាំងនៅកំរិតតំបន់ និងពិភពលោក ត្រូវតែមានបំពេញបន្ថែមដោយ យុទ្ធសាស្ត្រមួយសំរាប់បង្កើនសមត្ថភាពប្រកួតប្រជែងរបស់ប្រទេស និង ការធ្វើពិពិធកម្មទីផ្សារ និងផលិតផល ។ ដោយទទួលស្គាល់ពីធនធានមានកំរិតរបស់រដ្ឋាភិបាល គំរោងជំនួយពាណិជ្ជកម្ម (Aid for Trade) អាចជាជំនួយមួយដល់រដ្ឋាភិបាល ក្នុងការផ្តល់ហិរញ្ញប្បទានដល់គំរោងហេដ្ឋារចនាសម្ព័ន្ធដ៏ចាំបាច់ សំរាប់ទាញយកប្រយោជន៍ពីឱកាសល្អខាងពាណិជ្ជកម្ម ។ ហិរញ្ញប្បទានធនាគារ គឺជាប្រភពទុនមួយទៀតដែលអាចប្រើបាន ហើយឥណទានសំរាប់ការនាំចេញ អាចជួយសង្គ្រោះអ្នកនាំចេញ ដែលរងគ្រោះដោយវិបត្តិ និងជួយពង្រឹងពាណិជ្ជកម្មទាំងមូលទៀតផង ។ ការធ្វើពិពិធកម្មទីផ្សារ ជាការងារចាំបាច់បំផុតដែលបានលើកឡើងជារឿយៗហើយ ជាពិសេសទីផ្សារទាំងឡាយដែលមិនធ្លាប់ពាក់ព័ន្ធពីមុនមក ក៏គួរសិក្សាស្រាវជ្រាវដែរ ។ កំណែទំរង់កាន់តែស៊ីជំរៅលើបែបបទសម្របសម្រួលពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែង គឺជាវិធានការមួយទៀត ដែលគ្រប់ភាគីគួរជួយជ្រោមជ្រែង ។ ការវិនិយោគបន្ថែមទៀត ក្នុងវិស័យកសិកម្ម អាចជួយកាត់បន្ថយផលប៉ះពាល់ខ្លះនៃវិបត្តិបច្ចុប្បន្ន និងវិបត្តិផ្សេងៗនាពេលអនាគត ៕

### តើអ្នកបានដឹងទេថា

***... ឧស្សាហកម្មកាត់ដេរនៅកម្ពុជាពីមុន បានទទួលផលប្រយោជន៍ ពីរបបកូតា និង វិធានការការពាររបស់សហរដ្ឋអាមេរិក ទល់នឹងផលិតផលរបស់ប្រទេសចិន?*** ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីសាច់កំណាត់គ្រប់មុខ (Multi-Fibre Agreement – MFA) ជាមួយសហរដ្ឋអាមេរិក នៅឆ្នាំ១៩៩៩ គឺជាចំនុចស្ទុះឡើងនៃការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា ។ កិច្ចព្រមព្រៀងនេះផុតកំណត់នៅឆ្នាំ២០០៤ ។វិធានការការពាររបស់សហរដ្ឋអាមេរិក ទល់នឹងការនាំចូលសំលៀកបំពាក់ពីប្រទេសចិន បានផុតកំណត់នៅខែធ្នូ ២០០៨ ។វិធានការនេះ បានជួយការពារ ការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា បន្តពីកិច្ចព្រមព្រៀង MFA បានមួយរយៈ ។ ការវិវត្តទាំងនេះ គួបផ្សំនឹងវិបត្តិក្នុងពេលបច្ចុប្បន្ន គឺជាមូលហេតុនៃការប្រយុទ្ធតស៊ូរបស់វិស័យកាត់ដេរកម្ពុជានាពេលសព្វថ្ងៃ ។

*ប្រភព: កម្មវិធីកំណែលំអរោងចក្រកម្ពុជា (២០០៥, ២០០៨)*

***... តំរូវការរថយន្ត និងទោចក្រយានយន្តនៅកម្ពុជា បានធ្លាក់ចុះយ៉ាងលឿន ចាប់តាំងពីខែឧសភា ឆ្នាំ២០០៨មក?*** កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃបរិមាណការនាំចូលរថយន្ត និងទោចក្រយានយន្ត បានធ្លាក់ចុះបន្ទាប់ពីកើនខ្ពស់បំផុតនៅខែឧសភា ២០០៨ ។ ក្រៅពីវិបត្តិបច្ចុប្បន្ន មូលហេតុនៃការធ្លាក់ចុះតំរូវការដ៏ខ្លាំងបែបនេះ រួមមាន ឥទ្ធិពលនៃការឡើងថ្លៃថាមពល ការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ ការធ្លាក់ចុះប្រាក់ចំណូលពិត និង ជាពិសេស ការធ្លាក់ចុះទំនុកចិត្តរបស់អាជីវករ និងអ្នកប្រើប្រាស់ ។

*ប្រភព: ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការវាយតំលៃរបស់បុគ្គលិក*